## ពិពណ៌នាពីប្រទេសកម្ពុជាតាមរយៈសៀវភៅរឿងរូបភាព : ទីនេះ និង ពេលនេះ

កម្មសិក្សា-រោងជាង ឪប៉ូល ប៊ូដេឪ ស្តីពីសៀវភៅរឿងរូបភាពដែលបង្រៀនដោយលោក សេរ៉ា

ជាអ្នកតែងនិពន្ធសៀវភៅរឿងរូបភាពបាន១២ចំណងជើង (ក្នុងនោះមានរឿង ផ្លូវទល់ច្រក, ទឹក និង ដី) និងជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យប៉ារី១, លោក សេរ៉ា នឹងបើកកម្មសិក្សាជាថ្មីលើកទី២របស់លោកនៅរាជធានីភ្នំពេញដែលជាទីក្រុងកំណើតរបស់លោក, បន្ទាប់ពីកម្មសិក្សាលើកទី១នៅឆ្នាំ២០០៥ ។

---

ខ្លឹមសារនៃកម្មសិក្សា

---

- ស្វែងយល់ពិខ្លឹមសារនៃសាច់រឿង : តើយើងមានបំណងនិយាយពីអ្វី ?
- តុបតែងឈុតឆាក : តើអធិប្បាយឈុតឆាកយ៉ាងដូចម្តេច ?
- បរិយាយសាច់រឿងតាមរយៈរូបភាព

ប្រការទាំងនេះ, តម្រូវអោយមានការងារមួយរៀបចំទុកជាមុនដោយបេក្ខជនចូលរួមជាសិស្ស : ឪខ្ញុំចង់អោយសិស្សជាងគំនូរដែលមករៀននិយាយរឿងពិតរបស់ពួកគេ, ជីវភាព, បំណង, សុបិនអាក្រក់ ,,, ដែលពួកគេកំពុងតែនិយាយនៅទីនេះ និង ពេលនេះ ។

ដើម្បីអោយមានលក្ខណៈងាយស្រួល, អ្នកចូលរួមរៀនសូត្រត្រូវរិះគិតរកប្រធានបទណាមួយ រឺ ទីកន្លែងណាមួយដែលពួកគេចង់គូរដូចជាផ្សារថ្មី, ភូមិគ្រឹះសម័យអាណានិគមណាមួយ, រោងចក្រនៅជុំវិញរាជធានីភ្នំពេញ, អ្នកលក់ដូរតាមថ្នល់, ទេសភាពវាលស្រែ, ប្រវត្តិស្នេហ៍មិនបានសំរេចណាមួយ,,, ។

តាមរយៈគំនិតទាំងនេះ, អ្នកតែងនិពន្ធទាមទារអោយមានការក្រិតទុកជាមុននូវកន្លែងដាក់រូបភាពអោយបានច្បាស់លាស់ ។

---

ចំណុចសំខាន់នៃការបោះពុម្ពផ្សាយ

---

ក្នុងឱកាសរៀនសូត្រនេះដែរ, លោក សេរ៉ា នឹងជួយដល់អ្នកតែងនិពន្ធទាំងឡាយណាដែលបានចូលរួមកម្មសិក្សា-រោងជាង ប៉ូល ប៊ូដេនាឆ្នាំ២០០៥ ដើម្បីអោយពួកគេយកការងាររបស់ខ្លួនដែលបានរៀបរាងហើយ មកកែលំអ និង អាចបោះពុម្ពផ្សាយចេញ ។

ទោះតាមរយៈការងារយ៉ាងណាក៏ដោយ, គោលដៅសំខាន់នៃកម្មសិក្សារបស់លោក សេរ៉ា គឺធ្វើយ៉ាងណាអាចបោះពុម្ពអត្ថបទកំរង (អត្ថសង្គហៈ) ដែលបង្ហាញអោយឃើញពីជាងគំនូរខ្មែរជាច្រើននាក់ក្នុងទំរងទំព័រមួយមានឈុតឆាក មួយ រឺ ពីរ ភ្ជាប់គ្នាទៅនឹងជីវប្រវត្តិរបស់អ្នកនិពន្ធ ។

កម្មសិក្សា-រោងជាងនេះរាប់ចូលជាវគ្គសិក្សា " ប៉ូល ប៊ូដេ " ដែលជាឈ្មោះអ្នកមានគំនិតផ្តួចផ្តើមកសាងបណ្ណាល័យជាតិកម្ពុជា, និងវគ្គសិក្សាទាំងនេះមានទិសដៅចូលរួមគាំទ្រដល់ការបោះពុម្ពផ្សាយសំរាប់កុមារនៅកម្ពុជា មានទាំងសំណេរ, គំនូរ, ការងារបកប្រែ និង ថែមទាំងមានការរៀបចំវគ្គសិក្សាផ្សេងៗដល់អ្នកមានអាជីពជាអ្នកបោះពុម្ពផ្សាយ, ដល់អ្នកបកប្រែភាសា និង ជាងគំនូរ ។

សហការណ៏រៀបចំដោយ : មជ្ឈមណ្ឌលវប្បធម៌បារាំងនៅកម្ពុជា ( បណ្ណាល័យពហុឯកសារ-មជ្ឈមណ្ឌលពត៌មាន) និង ផ្នែកសហប្រតិបត្តិការណ៏ និង សកម្មភាពវប្បធម៌នៃស្ថានទូតបារាំងនៅកម្ពុជា ( មូលនិធិសំរាប់ជំនួយជាអទិភាព V.A.L.E.A.S.E. ¦

# ពិពណ៌នាពីប្រទេសកម្ពុជាតាមរយៈសៀវភៅរឿងរូបភាព : ទីនេះ និង ពេលនេះ

កម្មសិក្សា-រោងជាង ៖ប៉ូល ប៊ូដេ៖ ស្តីពីសៀវភៅរឿងរូបភាពដែលបង្រៀនដោយលោក សេរ៉ា

ការបរិច្ឆេទសំរាប់វគ្គទាំងពីរ :

ពីថ្ងៃចន្ទ ទី៩ ដល់ថ្ងៃព្រហស្បតិ៍ទី១២ ខែមេសា និង ពីថ្ងៃពុធ ទី ១៨ ដល់ថ្ងៃសុក្រ ទី២០ ខែមេសា ២០០៧។

ការចុះឈ្មោះ ក្នុងវគ្គសិក្សានេះ សំរាប់ចូលរួមរៀន៧ថ្ងៃយ៉ាងទៀងទាត់ ។

ការសិក្សានេះត្រូវបានរៀបជាពីរវគ្គដោយសារថ្ងៃបុណ្យចូលឆ្នាំខ្មែរ

ម៉ោងពេល : ១៤ ដល់ម៉ោង ១៧

បេក្ខជនដែលអាចចូលរួមបាន : ជាងគំនូរក្រាហ្វិក, ជាងគំនូរ, អ្នកនិពន្ធសៀវភៅរូបភាព

បង្រៀនជាភាសា : ភាសាបារាំង និង ភាសាខ្មែរ

ចំនួនកម្មសិក្សាការី : ២០ នាក់

លក្ខខណ្ឌចូលរៀន : ឥតមានបង់ប្រាក់ និង ទាមទារអោយមានវត្តមានរៀងរាល់ពេល

បែបបទចុះឈ្មោះ :

បេក្ខជនទាំងឡាយដែលចាប់អារម្មណ៍លើវគ្គសិក្សានេះ អាចផ្ញើរបេក្ខភាពរបស់ខ្លួនមកអ្នកស្រី ម្យូរីយ៉ែល ពីហ្វតូ, នាយិកាបណ្ណាល័យ ពុហាឯកសារនៃមជ្ឈមណ្ឌលវប្បធម៌បារាំង រឺតាមអ៊ីមែល : muriel.piffeteau@ccf-cambodge.org

បេក្ខភាពម្នាក់ៗត្រូវភ្ជាប់មកជាមួយនូវឯកសារចំឡងមួយច្បាប់ស្តីពីការងារបច្ចុប្បន្ន ។

---

## សលាកប័ត្រចុះឈ្មោះ

កម្មសិក្សាសេរ៉ា

នាម :

គោត្តនាម :

ថ្ងៃខែឆ្នាំកំនើត :

មុខងារ :

ខ្ញុំបាទ, នាងខ្ញុំសុំចុះឈ្មោះវគ្គសិក្សាដែលបង្រៀនដោយលោក សេរ៉ា ពីថ្ងៃទី៩ ដល់ ១២ ខែមេសា និង ពីថ្ងៃទី ១៨ ដល់ថ្ងៃទី២០ ខែមេសា ២០០៧ ដែលនឹងប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលវប្បធម៌បារាំង ។ ខ្ញុំសន្យាថានឹងគោរពតាមម៉ោងពេលនៃការសិក្សានេះ ។

ធ្វើនៅ : ហត្ថលេខា :

តើអ្នកធ្លាប់រួមវគ្គសិក្សាជាមួយលោកសេរ៉ា ដែលបានប្រព្រឹត្តិទៅនៅមជ្ឈមណ្ឌលវប្បធម៌បារាំងកាលពីឆ្នាំ២០០៥ដែរ រឺ ទេ ? បាន - អត់

ការចុះឈ្មោះត្រូវធ្វើអោយបានមុនថ្ងៃទី៣១ មិនា ២០០៧ នៅមជ្ឈមណ្ឌលវប្បធម៌បារាំងនៅកម្ពុជា - បណ្ណាល័យពុហាឯកសារ - ២១៤ ផ្លូវកែវជា ភ្នំពេញ - ទូរសព្ទលេខ : ០១២ ៨០២ ៧០២- អ៊ីម៉ែល : muriel.piffeteau@ccf-cambodge.org

---